**សកម្មភាព** ៖ ល្បែងច្របល់កាត និងផ្គុំកាតរូបភាព

**សិក្សាសង្គម**

បំណិនទំនាក់ទំនង

(បំណិនរស់នៅក្នុងសង្គម និងទំនាក់ទំនងវិជ្ជមានជាមួយមនុស្សជុំវិញ)

**ចិត្តចលភាព**

បំណិនចលកតូច (ការហ្វឹកហាត់បង្កើនកម្លាំង សម្របសម្រួលសាច់ដុំដៃ និងភ្នែកសាច់ដុំភ្នែក)។

**គោលបំណង** ៖

**(សិក្សាសង្គម)** ប្រាប់ពីការងារងាយៗមួយចំនួន ដូចជាការឱ្យចំណីសត្វ ស្រោចដំណាំបោសសម្អាត ការងារផ្ទះបាយ គ្រូពេទ្យ ជាងឈើ ជាដើម។

**(ចិត្តចលភាព)** ប្រាប់ពីរបៀបធ្វើចលនាតាមបែបទម្រង់ផ្សេងៗ ដោយការធ្វើអ្វីមួយ ឬ ការលេងល្បែងផ្សេងៗ។

**កម្រិតសិក្សា** ៖ ទាប មធ្យម ខ្ពស់

**សៀវភៅ** ៖ ដកស្រង់ចេញពីរឿង "តើអ្នកចង់ធ្វើការងារអ្វី?"

**រយៈពេល** ៖ ៣០ នាទី

**ឧបករណ៍** ៖ បោះពុម្ពកាតរូបភាពការងារ (4-1-B, 4-1-C, 4-2-B, 4-2-C, 4-3-B, 4-3-C, 4-4-B, 4-4-C, 4-5-B, 4-5-C) បន្ទាប់មកអ៊ុតកាត កាត់កាតរូបភាពការងារតូចៗ រូបភាពការងារទាំងមូល។

**ការរៀបចំ** ៖ ចែក១ក្រុមកាតមួយឈុតមាន ៦រូបភាពការងារ បន្ទាប់មកច្របល់កាតរូបភាពការងារចូលគ្នាទាំងអស់។ ត្រូវបោះពុម្ពរូបភាពទាំងមូលបិទលើក្តាខៀន និងកាតសម្រាប់បង្ហាញឱ្យក្មេងៗមើលនៅពេលដែលអ្នកពន្យល់ពីរបៀបលេង។

**សេចក្តីណែនាំ៖**

1. បិទរូបភាពការងារនៅលើក្តាខៀនក្នុងថ្នាក់រៀនសិន។
2. បន្ទាប់ត្រូវពន្យល់ច្បាប់លេងឱ្យបានច្បាស់ជាមុនសិន ។
   i. ចែកក្មេងៗជាក្រុមដែលមានចំនួនទៅតាមការកំណត់របស់អ្នក។
   ii. ឱ្យក្មេងទាំងអស់អង្គុយជារង្វង់ ។
   iii. ចែកកាតរូបភាពក្នុង ១ក្រុមទទួលបាន ១ឈុតមានរូបភាពមនុស្ស ៦នាក់ ។

iv. ចាត់តាំងក្មេងម្នាក់ក្នុងក្រុមនៃក្រុមនីមួយៗឱ្យប្រចបល់កាតរូបភាពមនុស្សទាំងនោះដោយផ្កាប់រូបភាពចុះក្រោម ហើយដាក់ចំកណ្តាលវង់។ ប្រាប់ក្មេងក្នុងក្រុមដែលនៅសល់ទាំងអស់ត្រូវបិទភ្នែកជៀសវាងមើលឃើញកាតទាំងនោះ។

v. ជ្រើសរើសក្មេងណាម្នាក់ថ្មីទៀត ឬ ប៉ាវក៏បានដែរដើម្បីឱ្យបើកកាតមួយសន្លឹក បន្ទាប់មកផ្ងារវានៅចំកណ្តាលវង់ (រូបភាពការងារមួយមាន ៣ចំណែក)។

vi. ក្មេងដែលនៅបន្ទាប់ពីអ្នកបើកកាតដំបូងរាប់ពីខាងស្តាំទៅត្រូវចាប់យកកាតរូបភាពមួយសន្លឹកដែរ និងមើលថារូបភាពកាតត្រូវនៅខាងលើ ខាងក្រោម ឬ កណ្តាល ដើម្បីបានជារូបរាងពេញទាំងមូលជាមនុស្សតែម្តង បើមិនច្បាស់ទេ សូមឱ្យពួកគេមើលរូបភាពពេញនៅលើក្តារខៀន។

vii. ម្យ៉ាងវិញទៀត បើសិនក្មេងៗចាប់បានកាតរូបភាពប្រភេទខុសគ្នាសូមផ្កាប់ទុកវិញ។ ឧទាហរណ៍៖ អ្នកទី ១បើកកាតដំបូងជាកាតរូបភាពគ្រូពេទ្យ តែអ្នកទី ២បើកបានកាតរូបភាពគ្រូបង្រៀន មានន័យមិនដូចគ្នា។ ដូចនេះត្រូវទុកវិញ បន្តវេនអ្នកទី ៣ចាប់វិញម្តងរហូតបានកាតរូបភាពគ្រូពេទ្យពេញលេញ ។

3. ពួកគេលេងល្បែងហ្នឹងបានមួយសន្ទុះ ហើយចាប់ផ្តើមពន្យល់ម្តងទៀត ដើម្បីឱ្យកាន់តែច្បាស់។

**ការប្រែប្រួល៖**

កាតរូបអាចដាក់នៅចំកណ្តាលវង់ ដើម្បីឱ្យក្មេងមានការរីករាយ និងសប្បាយជាងហ្នឹងទៀត។ ក្មេងៗក្នុងក្រុមនីមួយៗត្រូវបន្តចាប់កាតម្នាក់ៗម្តង រហូតបានជារូបភាពពេញលេញមុនគេ ទើបក្រុមនោះជាក្រុមឈ្នះ។